PRIA Since 1982 — SILAKA — THE WORLD BANK

# ការស្វែងយល់អំពីអភិបាលកិច្ច

ជាប្រវត្តិសាស្ត្រ ពិសេសបន្ទាប់ពីសង្គ្រាមលោកលើកទីពីរ គេបានចាត់ទុកការងារគ្រប់គ្រងរដ្ឋក្នុងប្រទេសមួយ ជាការទទួលខុសត្រូវរបស់រដ្ឋាភិបាល ។ ក្របខ័ណ្ឌនយោបាយប្រជាធិបតេយ្យរបស់រដ្ឋាភិបាលបានស្នើសុំឱ្យមានមុខងារឯករាជ្យ ៣ យ៉ាង ដែលមានការទាក់ទងគ្នាទៅវិញទៅមក គឺ នីតិបញ្ញត្តិ នីតិប្រតិបត្តិ និង តុលាការ ។ ក្នុងសង្គមខុសៗគ្នា រយៈពេល ៥០ ឆ្នាំកន្លងទៅ មុខងារទាំងនេះត្រូវបានរៀបចំផ្សេងៗគ្នា ទោះបីជានៅរក្សាគោលបំណងរួមក៏ដោយ ។

ដោយមានការកើតឡើងនូវការបាត់ការទុកចិត្តពីប្រជាជនសាមញ្ញ ទៅលើស្ថាប័នរដ្ឋាភិបាល និង ដោយសមត្ថភាពរបស់ស្ថាប័នទាំងនេះក្នុងការឆ្លើយតបចំពោះផលប្រយោជន៍ និង ការរំពឹងទុកច្រើនយ៉ាងរបស់ប្រជាជនមានការធ្លាក់ចុះ ជាមួយនឹងភាពលំអៀងរវាងគោលនយោបាយរបស់រដ្ឋាភិបាល និង ការអនុវត្តកាន់តែរីកធំឡើងស្របគ្នានឹងការកើនឡើងនូវគម្លាតរវាងអ្នកក្រ និងប្រជាជនដែលគេមិនអើពើ ពីស្ថាប័នរដ្ឋាភិបាល រួមទាំងបញ្ហានៃភាពក្រីក្រដែលរកទីបញ្ចប់គ្មាន ការផាត់ចោល និងការមិនអើពើនៅប្រទេស ជាច្រើនក្នុងពិភពលោក និងដោយមានការកើនឡើងនូវសារៈសំខាន់ខាងផលប្រយោជន៍ជំនួញឯកជន គោលគំនិតនៃការគ្រប់គ្រងឥឡូវនេះ បានចាប់ផ្តើមដូរទៅជាទ្រឹស្តីអភិបាលកិច្ចវិញ ។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងអត្ថន័យកម្រិតបឋមនៃវិស័យអភិបាលកិច្ចដែលត្រូវបានបន្សុីគ្នាជាមួយមុខងាររបស់រដ្ឋ ហើយដែលស្តែងចេញជាលទ្ធផលថា អភិបាលកិច្ចល្អ គឺទាក់ទងនឹងដំណើរពេញលក្ខណៈរបស់រដ្ឋ និងស្ថាប័នរបស់ខ្លួន និង ការលើកស្ទួយសមធម៌ និងយុត្តិធម៌សង្គម ។

ធនាគារពិភពលោក គឺជាអ្នកនាំយកទស្សនៈអំពី "អភិបាលកិច្ចល្អ" ចូលទៅក្នុងកិច្ចការអភិវឌ្ឍន៍មុនគេ ក្នុងប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ ។ បទពិសោធន៍របស់ធនាគារ ចំពោះភាពបរាជ័យនៃគោលនយោបាយសេដ្ឋកិច្ចក្នុងបណ្តាប្រទេសអាហ្វ្រិក ធ្វើឱ្យធនាគារទម្លាក់ការបរាជ័យនេះទៅលើ "អភិបាលកិច្ចមិនល្អ " មានដូចជាអប្រសិទ្ធផលខាងផ្នែករដ្ឋបាល អំពើពុករលួយ ការខ្វះតម្លាភាព...។ល។ ក្នុងប្រទេសទាំងនេះ ។ ការបង្កើតចេញជាគោលគំនិតអំពីអភិបាលកិច្ចមិនល្អ បាននាំឱ្យមានការរៀបចំគោលគំនិតអំពីអភិបាលកិច្ចល្អ ដែលដាក់បញ្ចូលវិស័យជាច្រើន ដូចជាប្រសិទ្ធផលខាងផ្នែករដ្ឋបាល នីតិរដ្ឋ ការទទួលខុសត្រូវ និងតម្លាភាព ។ ទោះជាយ៉ាងណាក៏ដោយ ធនាគារមិនបានដាក់ "អភិបាលកិច្ចល្អ " ឱ្យពាក់ព័ន្ធជាមួយនឹងរបបនយោបាយជាក់លាក់ណាមួយទេ ។

ការពាក់ព័ន្ធរវាង " អភិបាលកិច្ចល្អ " និងលទ្ធិប្រជាធិបតេយ្យ មានការជំរុញយ៉ាងជាក់ស្តែង ឱ្យចូលទៅក្នុងការងារអភិវឌ្ឍន៍ តាមរយៈភ្នាក់ងារផ្តល់ជំនួយទ្វេភាគី ដោយបង្កើតនូវលក្ខខណ្ឌជំនួយ ដើម្បីឱ្យមានការបោះឆ្នោតជាទៀងទាត់ ការលើកស្ទួយសិទ្ធិមនុស្ស និង នីតិរដ្ឋ ។

UNDP ចាត់ទុកអភិបាលកិច្ចល្អ ថាជាអត្ថិភាពនៃបណ្តាញរបស់ស្ថាប័នរដ្ឋាភិបាល រួមជាមួយច្បាប់ និងបទបញ្ញត្តិ ក្នុងការរួមគ្នាបង្កើត និង ការពារបរិស្ថានសង្គមដែលជាមូលដ្ឋាននៃការអភិវឌ្ឍរបស់មនុស្ស និងសម្រាប់ក្រុមទាំងអស់នៅក្នុងសង្គម ។ ដូច្នេះអភិបាលកិច្ចល្អ គឺជាសំណុំរងមួយរបស់អភិបាលកិច្ច ដែលធនធានសាធារណៈ និងបញ្ហាផ្សេងៗត្រូវបានគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាព ប្រសិទ្ធផល និងឆ្លើយតបទៅនឹងតម្រូវការរបស់សង្គម ។ ដូច្នេះការចូលរួមរបស់សាធារណជន ក្នុងការដាក់ឥទ្ធិពលលើការសម្រេចចិត្ត តម្លាភាព និងការទទួលខុសត្រូវ គឺជាចំណុចធំៗ/សញ្ញាសម្គាល់នៃអភិបាលកិច្ចល្អ (UNDP ឆ្នាំ ១៩៩៧) ។

ហេតុដូច្នេះ អភិបាលកិច្ចល្អមិនមែនត្រឹមតែជាការកែទម្រង់សេវាសាធារណៈ ប្រសិទ្ធផល និងប្រសិទ្ធភាព នៃការចំណាយថវិការបស់បណ្តាភ្នាក់ងាររដ្ឋប៉ុណ្ណោះទេ ប៉ុន្តែគឺជាការចូលរួម និងជាសម្លេងរបស់អ្នកក្រ ប្រជាជនដែលគេមិនអើពើ និង ពលរដ្ឋដែលមានតំណាងតិចតួចផងដែរ ។ ក្នុងការបកស្រាយអំពីគោលការណ៍នៃអភិបាលកិច្ចល្អ ត្រូវចងចាំនូវចំណុចខាងក្រោម :

- ការការពារសិទ្ធិមនុស្សជាសកល
- ការលើកស្ទួយសមធម៌ និងឱកាសស្មើៗគ្នា
- នីតិរដ្ឋដែលគេអនុវត្តជាលក្ខណៈមិនរើសអើង
- ប្រព័ន្ធតុលាការមានប្រសិទ្ធផល មិនលំអៀង និងដំណើរការកាត់ក្តីឆាប់រហ័ស
- តម្លាភាពក្នុងការអនុវត្តមុខងាររបស់ស្ថាប័ន និងមន្ត្រីសាធារណៈ (សិទ្ធិទទួលព័ត៌មាន)
- ការទទួលខុសត្រូវលើការសម្រេចចិត្តទៅលើបញ្ហា និងធនធានសាធារណៈ ដែលអ្នកដឹកនាំ និងមន្ត្រីសាធារណៈបានធ្វើ
- ការធ្វើវិមជ្ឈការអំណាចធនធាន និងអំណាចនៃការសម្រេចចិត្ត ទៅឱ្យកម្រិតមូលដ្ឋាន និង អង្គភាពមូលដ្ឋាននៅតាមជនបទ និងនៅតំបន់ប្រជុំជន ។

- ការចូលរួមរបស់ប្រជាពលរដ្ឋ និងការបញ្ចូលប្រជាពលរដ្ឋ ទៅក្នុងការជជែក ស្តីអំពីគោលនយោបាយ និង ជម្រើសសាធារណៈ ។

## វិស័យអភិបាលកិច្ច

របៀបវារៈនៃអភិបាលកិច្ចល្អមានភាពធំទូលំទូលាយ ។ វិសាលភាពនៃបញ្ហាអភិបាលកិច្ចពីកម្រិតមូលដ្ឋានដល់ថ្នាក់ជាតិមានច្រើន ។ ដើម្បីឱ្យមានភាពជាក់លាក់ ឯកសារនេះ បានផ្តោតលើវិស័យចំនួនបីនៃអភិបាលកិច្ច :

- **គោលនយោបាយសាធារណៈ**
- **ភាពទទួលខុសត្រូវ**
- **ការគ្រប់គ្រងតាមមូលដ្ឋានរបស់ខ្លួន**

វិស័យទាំងបីនេះ មានការពាក់ព័ន្ធធំសម្បើម នៅក្នុងបរិបទ នាពេលបច្ចុប្បន្ន (សម័យទំនើប) ។

### ១_ គោលនយោបាយសាធារណៈ

រដ្ឋនីមួយៗបង្កើតច្បាប់ គោលនយោបាយ និង កម្មវិធីជាច្រើន ស្តីពីសុខុមាលភាពប្រជាជន ។ ភាគច្រើននៃច្បាប់ គោលនយោបាយ និង កម្មវិធីទាំងនេះ បានធ្វើឡើងជាពិសេស ដើម្បីផលចំណេញដល់អ្នកក្រីក្រ និងអ្នកដែលគេមិនអើពើ ។ ទោះជាយ៉ាងណាក៏ដោយ លក្ខណៈទូទៅរបស់រដ្ឋមួយ នៅពេលវិវត្តតាមពេលវេលាបានបង្កើតស្ថានភាពមួយដែលភាគច្រើននៃគោលនយោបាយ និង កម្មវិធីដែលមានចេតនាល្អនេះ បានទទួលរងនូវភាពអន្តរាយ ។ រដ្ឋដែលគេបង្កើតឡើង ដោយយកគោលនយោបាយសេរីភាព និងសុខុមាលភាពនោះ នៅពេលវិវត្តទៅតាមពេលវេលារាប់រយឆ្នាំ ក្លាយទៅជាយន្តការបម្រើឱ្យមនុស្សមួយក្តាប់តូចដែលមានទ្រព្យស្តុកស្តម្ភ និងមានបុព្វសិទ្ធិ ។ ក្រៅពីកំណត់យកធ្វើជាផលប្រយោជន៍របស់ខ្លួនពីសំណាក់ក្រុមជនដែលមានទ្រព្យស្តុកស្តម្ភ ចរិតនៃការបង្កើតគោលនយាបាយ **នៅតែមិនមាន**ភាពជិតស្និទ្ធទៅនឹងប្រជាជនសាមញ្ញនោះទេ ។ ទាំងថ្នាក់ជាតិ និងថ្នាក់ខេត្ត ការិយាធិបតេយ្យតែងពាក់ព័ន្ធនឹងអំណាចបង្កើតគោលនយោបាយ ដែលគេរំពឹងថានឹងនាំយកផលប្រយោជន៍មកជូនប្រជាជនសាមញ្ញ ។ ដំណើរនៃការបង្កើតគោលនយោបាយ ដែលមិនឱ្យមានការចូលរួមធ្វើការសម្រេចចិត្តពីសំណាក់ប្រជាជនបែបនេះ តែងបានទទួលបរាជ័យ ក្នុងករណី ជាច្រើនទាក់ទងនឹងការយល់ដឹងពីសេចក្តីត្រូវការរបស់ពួកគេ ។ ចំណុចខាងក្រោមនេះ គឺជាវិស័យទាំង ៣ នៃគោលនយោបាយសាធារណៈដែលយកប្រៀបលើប្រជាជនដែលទទួលភាពមិនអើពើនោះ ។

- ការមិនបញ្ចូលផលប្រយោជន៍ អាទិភាព និងកង្វល់នៃក្រុមជនដែលគេមិនអើពើ នៅក្នុងការសរសេរលម្អិតអំពីគោលនយោបាយសាធារណៈ
- ឧបសគ្គក្នុងការអនុវត្តគោលនយោបាយ
- គោលនយោបាយ ដែលគេសង្កេតឃើញមានការគាបសង្កត់ពីក្រុមមួយចំនួនក្នុងសង្គម ។

យ៉ាងណាក៏ដោយ អង្គការសង្គមស៊ីវិលបានស៊ើបអង្កេត និងដាក់សម្ពាធលើរដ្ឋ ដើម្បីពង្រីកវិសាលភាពនៃដំណើរការធ្វើគោលនយោបាយសាធារណៈ ដើម្បីដាក់ចូលផលប្រយោជន៍របស់ក្រុមជនដែលគេមិនបានអើពើ ដែលមិនមានក្នុង ខ ចែងក្នុងគោលនយោបាយបច្ចុប្បន្ន ។ ក្នុងពេលជាមួយគ្នានេះ មានការខំប្រឹងប្រែងអនុវត្តគោលនយោបាយដែលមានស្រាប់ និងការប្រឆាំងចំពោះគោលនយោបាយដែលគេសង្កេតឃើញថាមានការគាបសង្កត់ ។ យើងសង្កេតឃើញថា ចលនាសង្គម និង អង្គការសង្គមស៊ីវិលជាច្រើនដែលតែង បានយកចិត្តទុកដាក់លើបញ្ហាបរិស្ថាន យេនឌ័រ និងសុខភាព ។ល។ បាននាំប្រជាជនដែលរងផលប៉ះពាល់ មកនៅជួរមុខគេ ហើយបានដាក់សម្ពាធទៅលើរដ្ឋាភិបាលឱ្យទទួលយកមតិរបស់ពួកគេ ។ ជាលទ្ធផល ការបង្កើត និងការអនុវត្តគោលនយោបាយដែលប្រើវិធីពីលើមកក្រោម បានទទួលរងឥទ្ធិពលពីក្រោមមកលើវិញ ។

## ២. ការទទួលខុសត្រូវ

សំណួរអំពី **ការទទួលខុសត្រូវ** មានភាពដូចគ្នានឹងបញ្ហានៃអភិបាលកិច្ចដែរ គឺជាការឆ្លុះបញ្ចាំងឱ្យឃើញនូវស្ថានភាពអភិវឌ្ឍន៍នៃលិទ្ធិប្រជាធិបតេយ្យដែលប្រាសចាកពីនីតិវិធី និងគោលដៅរបស់វា ។ រដ្ឋធម្មនុញ្ញបង្កើតឱ្យមានសិទ្ធិប្រជាធិបតេយ្យ តាមរយៈការលើកស្ទួយសមភាព ការផ្តល់ឱ្យដោយស្ថាប័នសាធារណៈ ការលើកស្ទួយផលប្រយោជន៍រួម និយាយឱ្យខ្លីគឺការទទួលខុសត្រូវលើការបង្កើតឱ្យមានបរិយាកាសមួយដែលប្រជាពលរដ្ឋអនុវត្តសិទ្ធិប្រជាធិបតេយ្យរបស់ខ្លួន និង កែលម្អការរស់នៅពីសំណាក់រដ្ឋដែលជាអ្នកផ្តល់នូវផលប្រយោជន៍ខាងកិច្ចអភិវឌ្ឍន៍ ហើយដែលត្រូវចេញជារូបរាង នៅក្នុងដើមទសវត្សនៃឯករាជ្យ ។ មិនចាំបាច់និយាយបែបនេះនោះគឺទាមទារឱ្យតំណាងជាប់ឆ្នោត និង មន្ត្រីព្រមទាំងស្ថាប័នសាធារណៈ ឱ្យមានការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ ។ ថ្វីត្បិតតែមានអភិបាលកិច្ចមានលក្ខណៈប្រជាធិបតេយ្យ និង ការផ្តល់សិទ្ធិតាមរយៈរដ្ឋធម្មនុញ្ញក៏ដោយ ក៏ភាពមិនទទួលខុសត្រូវរបស់រដ្ឋចំពោះប្រជាជនខ្លួន ដែលបង្ហាញឡើងតាមរយៈភាពព្រងើយកន្តើយ ឬតាមរបៀបការធ្វើកិច្ចការបន្តរបស់ខ្លួន បានធ្វើឱ្យមានការមិនពេញចិត្តក្នុងចំណោមប្រជាជនចំពោះរដ្ឋ និង ចំពោះ

បណ្តាភ្នាក់ងាររបស់រដ្ឋ ។ អារម្មណ៍មិនពេញចិត្តនេះ បានលេចឡើងក្នុងសម័យទំនើបជាលក្ខណៈសកម្មភាពរួមគ្នានៅក្នុងទីលានសាធារណៈ ។

## ៣~ ការគ្រប់គ្រងមូលដ្ឋានខ្លួនឯង

ក្នុងប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ វិមជ្ឈការ និង ការចែករំលែកអំណាចទៅថ្នាក់ក្រោម បានដាក់សម្ពាធឱ្យមានការគ្រប់គ្រងដោយខ្លួនឯងនៅតាមមូលដ្ឋាន ។ អាស្រ័យមានអាណត្តិនៃស្ថាប័ននានាដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ វាហាក់ដូចជាឱកាសខ្ពស់ ដែលអភិបាលកិច្ចល្អក្លាយជាក្តីបារម្ភធំមួយ នៅកម្រិតមូលដ្ឋាន ក្នុងស្ថាប័នទាំងនេះ ។ ទោះបីជាក្រោយពីមានវិសោធនកម្មរដ្ឋធម្មនុញ្ញ ដែលបានអនុម័តដើម្បីឱ្យអនុវត្តការផ្លាស់ប្តូរនៅក្នុងអភិបាលកិច្ចមូលដ្ឋាន និងធ្វើឱ្យវិមជ្ឈការដំណើរការក៏ដោយ សមត្ថភាពនៃការធ្វើការសម្រេចចិត្តរបស់អង្គភាពមូលដ្ឋាន នៅមានកម្រិតនៅឡើយ ក្នុងកិច្ចប្រតិបត្តិជាច្រើន ។